# ប្រាសាទសួរព្រ័ត្រ ឬនាង១២ និងតួនាទី

តើប្រាសាទសួរព្រ័ត្រ ឬប្រាសាទនាង១២ កសាងឡើងដើម្បីអ្វី និងមានតួនាទីយ៉ាងដូចម្តេច?

ប្រាសាទសួរព្រ័ត្រមានទីតាំងស្ថិតនៅក្នុងបរិវេណក្រុងអង្គរធំ ខាងមុខលានដំរី ឬខាងលិចប្រាសាទឃ្លាំងខាងជើង និងឃ្លាំងខាងត្បូង (រូបលេខ១)។ ប្រាសាទសួរព្រ័ត្រជាប្រាសាទមួយដែលមានលក្ខណៈប្លែកពីប្រាសាទដទៃបន្តិច ត្រង់ថាប្រាសាទនេះជាក្រុមប្រាង្គ១ៗដាច់ពីគ្នា ហើយរត់ត្រង់ជួរគ្នាពីជើងមកត្បូង។ ប្រាសាទនេះមានប្រាង្គចំនួន១២ បើគិតលើអ័ក្សផ្លូវកើតលិចពីក្លោងទ្វារជ័យមកជណ្តើរឡើងទៅរកព្រះរាជវាំង យើងឃើញថាប្រាង្គចំនួន៦ស្ថិតនៅខាងត្បូង (រូបលេខ២) និងប្រាង្គ៦ទៀតនៅខាងជើង(រូបលេខ៣)។ យើងពុំមានសិលាចារឹកបង្ហាញអំពីការស្ថាបនាដោយអង្គក្សត្រណាទេ នៅឆ្នាំណាដែលពិសេស គឺពុំមានការបកស្រាយអំពីតួនាទីរបស់ប្រាសាទឬប្រាង្គទាំង១២នេះទេ។ តាមលក្ខណៈសំណង់ អ្នកស្រាវជ្រាវភាគច្រើនបានអោយកាលបរិច្ឆេទប្រាសាទនេះស្ថិតនៅក្នុងរចនាបថបាយ័ន្ត ពោលគឺក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ (១១៨១គ.ស-១២២០គ.ស) ដែលព្រះអង្គបានសង់បន្ថែមកំពែងក្រុងអង្គរធំ ធ្វើអំពីថ្មបាយក្រៀម ក្លោងទាំង៥ ប្រាសាទតាមជ្រុងកំពែង ប្រាសាទបាយ័ន្ត ព្រះលានដំរីបន្តភ្ជាប់ពីក្លោងទ្វារខាងកើតរបស់រាជវាំង និងប្រាសាទសួរព្រ័ត្រជាដើម។

ប្រាង្គទាំង១២របស់ប្រាសាទនេះមានប្លង់ជាចតុកោណកែង ធ្វើអំពីថ្មបាយក្រៀមលម្អដោយទ្វារនៅទិសសំខាន់បន្តដោយសំណង់លយទៅមុខ (រូបលេខ៤) មានបង្អួចនៅទិសទាំង៣ផ្សេងទៀត និងហោជាងធ្វើអំពីថ្មភក់ពណ៌ប្រផេះ មានកំពូលចំនួន៣ថ្នាក់ ហើយដំបូលកោងរាងជាស្រទបចេក (រូបលេខ៥)។ ប្រាង្គទាំង១២នេះខ័ណ្ឌដាច់ពីគ្នាដោយអ័ក្សផ្លូវពីក្លោងទ្វារជ័យមកក្លោងទ្វារបរមរាជវាំង។ នៅខាងជើងមាន៦ប្រាង្គ បើយើងរាប់ពីខាងជើងបង្អស់ពីប្រាង្គលេខ១ដល់លេខ៥ គឺប្រាង្គទាំង៥នោះបែរមុខទៅទិសខាងលិច

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ឆ្ពោះទៅរាជវាំង និងលានដំរី។ រីឯប្រាង្គទី៦បែរមុខទៅទិសខាងត្បូងខុសគេ។ ចំណែកក្រុមប្រាង្គខាងត្បូងគឺដូចគ្នា បើរាប់ពីត្បូងមកជើង ពីលេខ១ដល់លេខ៥ ប្រាង្គទាំងនោះបែរទៅទិសខាងលិច ហើយប្រាង្គទី៦បែរទៅទិសខាងជើង ឈមនិងប្រាង្គទី៦នៅក្រុមខាងជើង។ ចំនុចនេះជាបញ្ហាដែលគេពិបាកនិងគិតថា ហេតុអ្វីបានជាគេស្ថាបនាប្រាសាទនេះឱ្យមានលក្ខណៈបែបនេះ?

## អំពីការអភិរក្ស និងជួសជុល

តាមរបាយការណ៍របស់សាលាបារាំងចុងបូព៌ាបង្ហាញថា ក្រុមប្រាង្គប្រាសាទសួរព្រ័ត្រនេះត្រូវបានសិក្សា និងអភិរក្សដោយការទល់ទ្រ និងបន្ថែមផ្នែកដែលបាត់។ គេបានអនុវត្តការងារនេះនៅឆ្នាំ១៩៥៥។[១] ក្រោយមកមានការអភិរក្សជាបន្តបន្ទាប់ដោយស្ថាប័នបារាំងរហូតដល់ទសវត្សទី៧០។[២] ដោយសារសង្គ្រាម កិច្ចការអភិរក្សប្រាសាទក្នុងតំបន់អង្គរបានផ្អាកអស់រយៈពេលជិត២០ឆ្នាំ។ ក្រោយការចុះបញ្ជីតំបន់អង្គរជាសម្បត្តិបេតិកភ័ណ្ឌពិភពលោកក្នុងឆ្នាំ១៩៩២ មានការបង្កើតអាជ្ញាធរជាតិអប្សរាសម្រាប់គ្រប់គ្រងតំបន់អង្គរ។ ក្រោយមកមានអង្គការអន្តរជាតិជាច្រើន ក៏បានមកចូលរួមសហការលើការងារស្រាវជ្រាវអភិរក្ស និងជួសជុលប្រាសាទជាច្រើន។ ចំពោះប្រាសាទសួរព្រ័ត្រត្រូវបានសិក្សា ធ្វើកំណាយបុរាណវិទ្យា និងជួសជុលដោយអង្គការជប៉ុនហៅថា JSA (The Japanese Government Team for Safeguarding of Angkor) ដោយសហការនឹងអាជ្ញាធរជាតិអប្សរាចាប់ពីឆ្នាំ១៩៩៤។[៣] គេបានជួសជុលលម្អិតលើប្រាង្គ N1 និងមានកិច្ចអភិរក្សលើប្រាង្គដទៃដែរ។

## អំពីតួនាទី

---

[១] EFEO 1917-1956.

[២] J. Dumarçay 1988

[៣] Nakagawa Takesi et al., 2005

អត្ថបទដោយ៖ សុខ កែវ សុវណ្ណាក៉

ពិតណាស់ រហូតមកដល់សព្វថ្ងៃនេះ យើងនៅតែមានមន្ទិលចំពោះតួនាទីរបស់ប្រាសាទសួរព្រ័ត្រ ឬនាង១២នេះនៅឡើយ។ ម៉្យាងទៀត ពុំមានសិលាចារឹកណាមួយបង្ហាញអំពីតួនាទី ឬការប្រើប្រាស់ប្រាសាទនេះដើម្បីអ្វីដែរ។

តាមការរៀបរាប់អំពីរឿងព្រេងក្នុងតំបន់របស់អ្នកភូមិស្រុក គេតែងភ្ជាប់ប្រាសាទនេះទៅនឹងរឿងពុទ្ធិសែននាងកង្រី ឬនាងទាំង១២ដែលជាបុត្រីចិញ្ចឹមរបស់យក្ខិណីឈ្មោះសន្ធមា ដែលជាហេតុនាំឱ្យគេបង្កើត និងហៅទីកន្លែងមួយចំនួនក្នុងតំបន់អង្គរធំនេះទៅតាមភាពជាក់ស្តែង ដូចជា កស្សិណាផ្នា (សន្ធមា) ឬបឹងផ្នា (អ្នកភូមិមួយចំនួនហៅត្រពោកយាយមា) និងដោះយាយមា (ទួលធំមួយនៅពីក្រោយរាជវាំង) ជាដើម។ ទាំងនេះគ្រាន់តែជារឿងព្រេងប្រឌិតឡើងដោយមនុស្សសម័យក្រោយ (អាចសតវត្សទី១៧ឬ១៨) ឱ្យស្របទៅនឹងទិដ្ឋភាព និងសំណង់អ្វីដែលមានលក្ខណៈដូចនឹងសាច់រឿង។

លោក Mourice Glaire[៨] បង្ហាញថា មុខនាទីរបស់ប្រាសាទនេះនៅមិនទាន់ដឹងទេ។

ឯកសារសំខាន់មួយ គឺរបាយការណ៍កំណត់ហេតុរបស់លោកជីវ តាក្វាន់[៩] ដែលបានសរសេររៀបរាប់អំពីទំនៀមទំលាប់របស់អ្នកស្រុកចេនឡាក្នុងឆ្នាំ១២៩៦។ លោកបានរៀបរាប់ថា ប្រាសាទសួរព្រ័ត្រគឺជាកន្លែងដាក់មនុស្សដែលមានក្តីក្តាំនឹងគ្នា។ គេឱ្យអ្នកមានក្តីក្តាំទាំងនោះស្នាក់នៅក្នុងប្រាង្គរាងខ្លួនរយៈពេល៣ទៅ៤ថ្ងៃ។ ប្រសិនបើនរណាម្នាក់កើតជំងឺដូចជាក្តៅខ្លួនជាដើម នោះគេវិនិច្ឆ័យថាអ្នកឈឺនោះបានប្រព្រឹត្តខុស គេនឹងដាក់ទោសទណ្ឌតាមកំហុសនោះ។ បើវិភាគលើរយៈពេលនៃការមកដល់របស់លោក ជីវ តាក្វាន់ គឺមានរយៈពេលជិត៧០ឆ្នាំ ក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៧ (១១៨១ គ.ស-១២២០គ.ស) ពោលគឺស្ថានការនយោបាយ និងទំនៀមទំលាប់ផ្សេងៗស្ទើរតែផ្លាស់ប្តូរអស់ទៅហើយ។ ដូចនេះការប្រើប្រាស់ប្រាសាទសួរព្រ័ត្រឬនាង១២ គឺជាការផ្លាស់ប្តូរថ្មីក្រោយ៧០ឆ្នាំក្រោយ។

---

[៨] Glaize, Maurice 2013

[៩] លី ធៀមតេង ១៩៧៣:៤៣

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ដោយយោងតាមលក្ខណៈសំណង់ និងការរកឃើញបដិមាលោកកេស្វរៈចំនួន៤នៅក្បែរប្រាង្គ S1 S2 និងS5 នៅឆ្នាំ១២៦[៦] ដោយសាលាបារាំងចុងបូព៌ា និងការរកឃើញបដិមា២ផ្សេងទៀតនៅក្បែរប្រាង្គផ្សេងគ្នា (រូបលេខ៦)[៧] ក្នុងឆ្នាំ១៩៩៩ ដោយក្រុម JSA នៅក្បែរប្រាង្គN1 យើងអាចសន្និដ្ឋានថា ប្រាសាទសួរព្រ័ត្រអាចស្ថាបនាឡើងដើម្បីឧទ្ទិស និងតម្កល់បដិមាលោកេស្វារៈ ឬអវលោកិតេស្វរៈ ដូចគ្នាទៅនឹងចម្លាក់លើជញ្ជាំងខាងលិចរបស់ប្រាសាទបន្ទាយឆ្មារដែរ។

ម៉្យាងទៀត តាមយោបល់របស់ខ្ញុំ ប្រាសាទសួរព្រ័តនេះអាចកសាងឡើងតាមដំណើរគោចររបស់ព្រះអាទិត្យក្នុងរយៈពេល១ឆ្នាំដូចនៅប្រាសាទអង្គរវត្តដែរ[៨] យើងអាចមើលឃើញព្រះអាទិត្យរះចំចំណុចតែមួយ (សមរាត្រី) នៅលើកំពូលរបស់ក្លោងទ្វារជ័យពីក្លោងទ្វារចូលបរមរាជវាំង។ ចំណែកប្រាង្គទាំង១២ គឺតំណាងឱ្យខែទាំង១២ ដោយ៦ខែនៅខាងត្បូង និង៦នៅខាងជើង។ វាជាប្រាសាទតំណាងឱ្យទេពនិករទាំង១២ខែ ព្រោះនៅជញ្ជាំងខាងក្រោម ផ្នែកខាងក្រោយរបស់ខឿនស្ដេចគម្វង់ (ព្រះយម) ក៏មានចម្លាក់ទេពស្រី១២នាក់ ជិះលើសត្វផ្សេងៗគ្នាដែរ ។

ចំនុចទាំងនេះគ្រាន់តែសម្មតិកម្ម និងការវិភាគបណ្ដោះអាសន្នតែប៉ុណ្ណោះ យើងមិនទាន់ច្បាស់ថា ចំនុចណាមួយដែលសមស្របទៅនឹងតួនាទីរបស់ប្រាសាទនេះក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ទេ។ យើងត្រូវស្វែងរកភស្តុតាងបន្ថែមដើម្បីពង្រឹងលើសម្មតិកម្មទាំងនេះ ពិសេសបើអាចមាន គឺភស្តុតាងបញ្ជាក់ដោយសិលាចារឹក។

[៦] EFEO 1917-1956

[៧] Nakagawa Takesi et al., 2005:115

[៨] សុខ កែវ សុវណ្ណារ៉ា, ២០២១

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

## ឯកសារយោង

លី ធៀមតេង

១៩៧៣. កំណត់ហេតុរបស់ជីវ តាក្វាន់,បោះពុម្ពលើកទី៣, ទំព័រ, ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា

២០២១. *ទស្សនៈនៃការស្ថាបនាប្រាសាទអង្គរវត្តជាមួយចំនួន៦ និង១២*, ក្នុង AMS,ភ្នំពេញ។

EFEO

1917-1956. *Prasat Suor Prat*, RCA.

J. Dumarçay

1988. *Ducuments Graphiques de la Conservation d'Angkor 1963-1973*, EFEO, Paris

*Glaize, Maurice*

2013.*Prasats Suor Prat, in The Angkor Guide.*

Nakagawa Takesi et al.,

2005. *The Report on the Conservation and Restoration Work of Prasat Suor Prat Tower*, JSA

AMS
KHMER CIVILIZATION




រូបលេខ១៖ ប្លង់ទីតាំងប្រាសាទសួរព្រ័ត



រូបលេខ២៖ ប្រាង្គប្រាសាទសួរព្រ័តក្រុមខាងជើង



រូបលេខ៣៖ ប្រាង្គប្រាសាទសួរព្រ័តក្រុមខាងត្បូង



រូបលេខ៨៖ ប្រាង្គប្រាសាទសួរព្រ័ត



រូបលេខ៩៖ ប្រាង្គប្រាសាទសួរព្រ័ត

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៦៖ បដិមារកឃើញក្បែរប្រាង្គខាងជើង (JSA)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា